# មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ




## សិក្ខាសាលាតំរង់ទិស និងបណ្តុះបណ្តាល ស្តីពីការបង្ការវិជ្ជមាន
## និងការផ្តល់សេវាពន្យាកំណើតសំរាប់បុគ្គលិកនៃសេវាព្យាបាលជំងឺឱកាសនិយម និងព្យាបាលដោយ ឱសថ
## ប្រឆាំងមេរោគអេដស៍ និង គ្លីនិកសុខភាពគ្រួសារ

# The Orientation Workshop
# And Training in Positive Prevention and Birth Spacing
# for OI/ART and Family Health Clinic Staff

មន្ទីរសុខាភិបាលខេត្តកំពង់ស្ពឺ, ថ្ងៃទី ២៩-៣០ ខែ កញ្ញា ឆ្នាំ ២០១១

រៀបចំដោយ

សហការជាមួយ

ឧបត្ថម្ភដោយ

Healthy lives. Measurable results.

# សិក្ខាសាលាតំរង់ទិស និងបណ្តុះបណ្តាល ស្តីពីការបង្ការវិជ្ជមាន និងការផ្តល់សេវាពន្យាកំណើតសំរាប់បុគ្គលិកនៃសេវាព្យាបាលជំងឺឱកាសនិយម និង ព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ និង គ្លីនិកសុខភាពគ្រួសារ

## ១. គោលបំណងនៃសិក្ខាសាលាតំរង់ទិស

- ផ្សព្វផ្សាយពីគោលគំនិតសំខាន់ៗ ស្តីពីការបង្ការជាវិជ្ជមាន និងការផ្តល់សេវាពន្យាកំណើត នៅតាមសេវាព្យាបាលជំងឺឱកាសនិយម និងឱសថប្រឆាំងមេរោគអេដស៍ និងគ្លីនិកសុខភាពគ្រួសារ
- ផ្តល់ចំណេះដឹង និងជំនាញអំពីមធ្យោបាយពន្យាកំណើត ដល់បុគ្គលិកនៃសេវាព្យាបាលជំងឺឱកាសនិយម និងឱសថប្រឆាំងនឹងមេរោគអេដស៍ និងគ្លីនិកសុខភាពគ្រួសារ
- ពិភាក្សា និងឯកភាពលើយន្តការនៃការស្នើសុំធ្វើរបាយការណ៍ប្រើប្រាស់មធ្យោយពន្យាកំណើត និងការប្រមូលទិន្នន័យ សំរាប់តាមដានការអនុវត្តន៍

## ២. សមាសភាពចូលរួម

ក. គណអធិបតីចូលរួមក្នុងកម្មវិធីបើកសិក្ខាសាលា

- លោកសាស្រ្តចារ្យ **គុំ កាណាល់** ប្រធានមជ្ឈមណ្ឌលជាតិគាំទ្រមាតា និងទារក
- លោកវេជ្ជបណ្ឌិត **មាស វុឌ្ឍី** អនុប្រធានមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និង កាមរោគ
- លោកវេជ្ជបណ្ឌិត **អោ វណ្ណាថេន** ប្រធានមន្ទីរសុខាភិបាលខេត្តកំពង់ស្ពឺ

ខ. គ្រូឧទ្ទេសនាម និងសំរបសំរួលថ្នាក់ជាតិ និងខេត្ត

- លោកវេជ្ជ. សេង សុភាព អនុប្រធានការិយាល័យបច្ចេកទេសនៃ NCHADS
- លោកវេជ្ជ. គឹម ប៊ុណ្ណា ប្រធានផ្នែកផែនការនៃ NCHADS
- លោកវេជ្ជ. សំរិត សុវណ្ណរិទ្ធិ ប្រធានផ្នែកថែទាំជំងឺអេដស៍នៃ NCHADS
- លោកវេជ្ជ. សេង វុធី អនុប្រធានផ្នែកថែទាំជំងឺអេដស៍នៃ NCHADS
- លោកវេជ្ជ. ង៉ូវ បូរ៉ា អនុប្រធានផ្នែកថែទាំជំងឺអេដស៍នៃ NCHADS
- លោកវេជ្ជ. ទូច សារុន មន្ត្រីផ្នែកថែទាំជំងឺអេដស៍នៃ NCHADS
- លោក ផាត់ វាសនា មន្ត្រីផ្នែកគ្រប់គ្រងទិន្នន័យនៃ NCHADS
- លោកវេជ្ជ. ហួន ធីន ប្រធានកម្មវិធីប្រយុទ្ធនឹងជំងឺអេដស៍ និងកាមរោគខេត្ត
- លោកវេជ្ជ. យ៉ន ឡុន មន្ត្រីកម្មវិធីប្រយុទ្ធនឹងជំងឺអេដស៍ និងកាមរោគខេត្ត

- លោក ថ្នល់ ស៊ន មន្ត្រីកម្មវិធីប្រយុទ្ធនឹងជំងឺអេដស៍ និងកាមរោគខេត្ត
- កញ្ញាវេជ្ជ. ប៉ាន់ អាន មន្ត្រីគាំពារមាតា និងទារកខេត្ត
- កញ្ញា សែ សុខន មន្ត្រីគាំពារមាតា និងទារកខេត្ត

គ. អ្នកសំរបសំរួលសិក្ខាសាលា

- លោក ខែម ម៉ៅ អនុប្រធានផ្នែករដ្ឋបាលនៃ NCHADS
- លោក កែវ វណ្ណៈ មន្ត្រីផ្នែកថែទាំជំងឺអេដស៍នៃ NCHADS
- លោកស្រី ភិន កញ្ញានា មន្ត្រីផ្នែករដ្ឋបាលនៃ NCHADS
- លោក ស៊ីម ម៉ា មន្ត្រីផ្នែករដ្ឋបាលនៃ NCHADS
- លោក កែ វិបុល មន្ត្រីផ្នែករដ្ឋបាលនៃ NCHADS
- លោកស្រី គូ សុភា មន្ត្រីផ្នែកហិរញ្ញវត្ថុនៃ NCHADS
- កញ្ញា ជឹម សុភាព មន្ត្រីផ្នែកហិរញ្ញវត្ថុនៃ NCHADS

ឃ. អ្នកចូលរួម

- មន្ទីរសុខាភិបាល,ស្រុកប្រតិបត្តិ និងមន្ទីរពេទ្យបង្អែកកំពង់ស្ពឺ ចំនួន ២៦រូប
- ស្រុកប្រតិបត្តិឧដុង្គ ចំនួន ១២រូប
- ស្រុកប្រតិបត្តិគងពិសី ចំនួន ១៣រូប
- អង្គការដៃគូ (WVC, NAPA និង CPN+) ចំនួន ០៣រូប

## ៣. សកម្មភាពក្នុងសិក្ខាសាលា

ក. ថ្ងៃទី១: ថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២០១១

❖ កម្មវិធីបើកសិក្ខាសាលា

- លោកវេជ្ជបណ្ឌិត **អោ វណ្ណថេន** ប្រធានមន្ទីរសុខាភិបាលខេត្តកំពង់ស្ពឺ មានចំណាប់អារម្មណ៍ក្នុងកម្មវិធីបើកសិក្ខាសាលា ដូចតទៅៈ លោកវេជ្ជបណ្ឌិត បានជំរាបជូនគណអធិបតី និងអ្នកចូលរួមទាំងអស់អំពីស្ថានភាពទូទៅ ដែលទាក់ទងនឹងសេវាសុខាភិបាលនៅក្នុងខេត្តកំពង់ស្ពឺ គឺមានស្រុកប្រតិបត្តិចំនួន ៣ស្រុក គឺ ស្រុកប្រតិបត្តិកំពង់ស្ពឺ, គង់ពិសី និងឧដុង្គ ហើយក្នុងស្រុកប្រតិបត្តិទាំងនោះ មានមន្ទីរពេទ្យបង្អែកទាំងអស់ និងមានមណ្ឌលសុខភាព សរុបទាំងអស់ចំនួន ៥០មណ្ឌល ដែលមានមណ្ឌលធ្វើតេស្តឈាមរកមេរោគអេដស៍ដោយស្ម័គ្រ និងរក្សាការសំងាត់ ចំនួន ៩កន្លែង មានគ្លីនិកជំងឺកាមរោគ ចំនួន ២កន្លែង ម្យ៉ាងទៀតមានក្រុមថែទាំតាមផ្ទះ និងសហគមន៍ ចំនួន ១៤ក្រុម ដែលគាំទ្រដោយអង្គការដៃគូចំនួន ៥អង្គការ ក្នុងចំណោមអង្គការដៃគូសរុប ចំនួន ៣៤អង្គការ ដែលបានគ្របដណ្តប់មណ្ឌលសុខភាពទាំង ៥០មណ្ឌលទូទាំងខេត្តកំពង់ស្ពឺ។ លោកបានបន្តទៀតថា រហូតដល់ចុងត្រីមាសទី២ ឆ្នាំ ២០១១ នេះ មានអ្នកជំងឺអេដស៍ និងអ្នកផ្ទុកមេរោគអេដស៍ ចំនួន ១៨២៥នាក់ ដែលក្នុងនោះ មានកុមារ ចំនួន ៤០១ នាក់។ ក្នុងចំណោម

អ្នកជំងឺអេដស៍ និងអ្នកផ្ទុកមេរោគអេដស៍ ចំនួន ១៨២៥ នាក់ មានអ្នកកំពុងព្យាបាលជំងឺឱកាសនិយម ចំនួន ៧៤៥នាក់ ដែលមានកុមារ ចំនួន ១៤៩នាក់ និង អ្នកកំពុងព្យាបាលដោយឱសថប្រឆាំងនឹងមេរោគអេដស៍ ចំនួន ១០៨០ ដែលមានកុមារចំនួន ២៥២នាក់ ។

០ លោកវេជ្ជបណ្ឌិត **មាស វុឌ្ឍី** អនុប្រធានមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ បានមានចំណាប់អារម្មណ៍ថា នេះជាលើកទី២ហើយ ដែលមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ បានសហការណ៍ជាមួយមជ្ឈមណ្ឌលជាតិគាំពារមាតា និងទារកលើការអនុវត្តន៍យុទ្ធសាស្ត្របង្ការជាវិជ្ជមាន (Positive Prevention) បន្ទាប់ពីបានសហការគ្នាប្រកបដោយភាពជោគជ័យលើការអនុវត្តន៍យុទ្ធសាស្ត្រឆ្លើយតបរួមគ្នា (Linked Response)។ ស្របជាមួយគ្នានេះដែលោកបានជំរាបអង្គសិក្ខាសាលាអំពីព័ត៌មានថ្មីពីការថែទាំ និងព្យាបាលជំងឺអេដស៍ មានដូចជាៈ អត្រាប្រេវ៉ាឡង់មេរោគអេដស៍ នៅឆ្នាំ ២០១១ គឺ 0,៨% ហើយព្រះរាជាណាចក្រកម្ពុជា សំរេចបានការផ្តល់ការព្យាបាលដោយឱសថប្រឆាំងនឹងមេរោគអេដស៍ ក្នុងចំណោមប្រជាជនទូទៅ ដែលមានអាយុចន្លោះពី ១៥ ទៅ ៤៩ឆ្នាំ លើសពី ៩០%។ ទន្ទឹមនឹងការសំរេចបានជោគជ័យទាំងនេះ យើងនៅតែមានបញ្ហាមួយចំនួនដែលទាក់ទងនឹងធនធានមនុស្ស ហេដ្ឋារចនាសម្ព័ន្ធ និងប្រាក់លើកទឹកចិត្ត។

០ លោកសាស្ត្រាចារ្យ គុំ កាណាល់ បានមានចំណាប់អារម្មណ៍ក្នុងសិក្ខាសាលានេះ ថាៈ ជាបឋមលោកបានឯកភាព ចំពោះមតិរបស់លោកវេជ្ជបណ្ឌិត មាស វុធី និងលោកវេជ្ជបណ្ឌិត អោ វណ្ណថេន ដែលបានលើកឡើងក្នុងកម្មវិធីនេះ។ ក្នុងឱកាសនេះ លោកបានរំលឹកថា ហេតុអ្វីបានជាយើងអនុវត្តនូវយុទ្ធសាស្ត្របង្ការជាវិជ្ជមាន សំរាប់អ្នកជំងឺអេដស៍ និងអ្នកផ្ទុកមេរោគអេដស៍ គឺដោយសារយើងមានផែនការច្បាស់លាស់ និងស្របទៅនឹងការប្តេជ្ញាចិត្តរបស់លោកជំទាវគតិព្រឹទ្ធបណ្ឌិត **ប៊ុនរ៉ានី ហ៊ុន សែន** ដែលបានប្តេជ្ញាថានឹងធ្វើអោយ សូន្យបី (Three Zero) នៅឆ្នាំ ២០១៥ ក្នុងការថែទាំ និងព្យាបាលជំងឺអេដស៍ នៅក្នុងព្រះរាជាណាចក្រកម្ពុជា គឺ សូន្យទី១: មិនអោយមានការរីករាលដាលមេរោគអេដស៍ ក្នុងចំណោមករណីថ្មី, សូន្យទី២: មិនអោយមានការឆ្លងមេរោគអេដស៍ថ្មីពីម្តាយទៅកូន និងសូន្យទី៣: បំបាត់ភាពរើសអើង ចំពោះអ្នកផ្ទុកមេរោគអេដស៍ និងអ្នកជំងឺអេដស៍។ លោកសាស្ត្រាចារ្យបានបញ្ជាក់បន្ថែមថា បច្ចុប្បន្នអ្នកប្រើប្រាស់សេវាសុខាភិបាល ជាពិសេសសេវាពន្យាកំណើត មានមិនទាន់ ៤០%ក្នុងចំណោមប្រជាជនទូទៅ ដោយមូលហេតុថាអតិថិជនមួយចំនួនមិនបានដឹងពីសេវានេះ ដោយសារអង្គភាពពាក់ព័ន្ធមិនបានផ្សព្វផ្សាយ ឬ ផ្សព្វផ្សាយដែរ តែមិនគ្រប់ជ្រុងជ្រោយ, អ្នកខ្លះដឹងហើយតែមិនចូលរួមប្រើប្រាស់ ដោយសារពួកគាត់មិនមានទំនុកចិត្តក្នុងការប្រើប្រាស់។ លោកបានរំលឹកផងដែរ អំពីមធ្យោបាយពន្យាកំណើត នៅក្នុងប្រទេសកម្ពុជា មានចំនួន ៩ ប្រភេទ ដែលក្នុងនោះ នៅសេវា OI/ART អាចផ្តល់ជូនអតិថិជន បានចំនួន ៣ប្រភេទៈ ទី១ គឺការប្រើថ្នាំលេប, ទី២ គឺការប្រើថ្នាំចាក់ និងទី៣ គឺការប្រើប្រាស់ស្រោមអនាម័យ ហើយលោកបន្ថែមថា ការប្រើប្រាស់ស្រោមអនាម័យគឺជាមធ្យោបាយដ៏មានអត្ថប្រយោជន៍ ចំពោះអ្នកផ្ទុកមេរោគអេដស៍ និងអ្នកជំងឺអេដស៍ ដោយហេតុថា វាអាចបង្ការការមានកូនដោយចៃដន្យ (មិនតាមបំណងប្រាថ្នា) និងបង្ការចំលងជំងឺកាមរោគនានា។ ទន្ទឹមនឹងនេះ គាត់បានរំលឹកថា សេវាពន្លូតកូន មិនមែនជាសេវាពន្យាកំណើតទេ។

❖ **ការណែនាំអោយស្គាល់គ្នា** បង្ហាញដោយលោកវេជ្ជបណ្ឌិត ទូច សារុន

- ❖ **ការបង្ហាញពីគោលបំណងនៃសិក្ខាសាលា** បង្ហាញដោយលោកវេជ្ជបណ្ឌិត សេង វុធី
- ❖ **ការបង្ហាញពីបច្ចុប្បន្នភាព និងស្ថានភាពមេរោគអេដស៍ និងជំងឺអេដស៍ នៅកម្ពុជា** បង្ហាញដោយលោកវេជ្ជបណ្ឌិត ទូច សារុន។ នៅចុងបញ្ចប់នៃការបង្ហាញរបស់គាត់ អ្នកចូលសិក្ខាសាលាបានសំណូមពរអោយអ្នកបង្ហាញ ជួយពន្យល់បន្ថែមអោយច្បាស់អំពីៈ អ្វីជាយុទ្ធសាស្ត្រ 3I's? តើយុទ្ធសាស្ត្រមានសារៈសំខាន់អ្វីខ្លះ ដល់អ្នកជំងឺអេដស៍?
- ❖ **ការបំពេញទំរង់ផ្សេងៗ ក្នុងការបង្ការជាវិជ្ជមាន** បង្ហាញដោយលោក ផាត់ វាសនា
- ❖ **គោលការណ៍នៃការពន្យាកំណើត** បង្ហាញដោយកញ្ញាវេជ្ជបណ្ឌិត ប៉ាន់ អាន។ នៅចុងបញ្ចប់ តំណាងអ្នកចូលរួមអញ្ជើញមកពីមន្ទីរពេទ្យបង្អែកឧដុង្គ បានសួរសំនួរចំនួន ២ៈ ទី១ គឺ តើមធ្យោបាយពន្យាកំណើតចំពោះអ្នកជំងឺអេដស៍ និងផ្ទុកមេរោគអេដស៍ប្រើតែស្រោមអនាម័យមួយមុខបានរឺទេ? លោកបានបន្ថែមថា ទូទៅ យើងត្រូវលើកទឹកចិត្តអ្នកជំងឺអោយប្រើប្រាស់ស្រោមអនាម័យ ព្រោះវាអាចបង្ការការចំលងជំងឺកាមរោគ និងការឆ្លងនៅមេរោគអេដស៍ប្រភេទផ្សេងៗទៀត ជាពិសេសមិនអោយមានកូនដោយចៃដន្យ បានប្រកបដោយប្រសិទ្ធិភាព និងសំនួរទី២ គឺ តើថ្នាំពន្យាកំណើតអាចមានប្រតិកម្ម ឬ អន្តរកម្មជាមួយឱសថប្រឆាំងនឹងមេរោគអេដស៍ដែររឺទេ? លោកវេជ្ជបណ្ឌិត សេង វុធី បានបញ្ជាក់ថា ឱសថ ARV (NVP) អាចបន្ថយប្រសិទ្ធិភាពនៃថ្នាំ COC និង POP
- ❖ **សិទ្ធិរបស់អ្នកជំងឺក្នុងការទទួលយកមធ្យោបាយពន្យាកំណើត** បង្ហាញដោយកញ្ញាវេជ្ជបណ្ឌិត ប៉ាន់ អាន
- ❖ **ប្រព័ន្ធការពន្យាកំណើត** បង្ហាញដោយកញ្ញាវេជ្ជបណ្ឌិត ប៉ាន់ អាន

**ក. ថ្ងៃទី២ៈ ថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ២០១១**

- ❖ **ឱសថពន្យាកំណើតដោយលេប** Oral Contraceptive (CoC and Emergency) កញ្ញា សែ សុខន
- ❖ **ការប្រើប្រាស់ឱសថពន្យាកំណើតដោយលេប** Oral Contraceptive(POP) កញ្ញា សែ សុខន។ នៅចុងបញ្ចប់នៃការបង្ហាញ អ្នកចូលរួមសិក្ខាសាលា បានសួរមួយចំនួនដែលទាក់ទងនឹងការបង្ហាញ ដូចជាៈ សំណួរទី១ តើផលរំខាននៃការប្រើ CoC និង POP មានរយៈពេលប៉ុន្មានថ្ងៃ? កញ្ញាបានឆ្លើយថា ជាទូទៅស្ត្រីភាគច្រើន អាចមានផលរំខានក្នុងរយៈពេលនៃការប្រើប្រាស់ ២ ទៅ ៣បន្ទះដំបូង។ សំណួរទី២ ផលរំខានដោយធ្លាក់ឈាមនៃការប្រើប្រាស់ CoC និង POP តើយើងគួរឈប់ប្រើថ្នាំដែររឺទេ? កញ្ញាបានប្រាប់ថា ភាគច្រើននៃស្ត្រីដែលបានប្រើប្រាស់ឱសថទាំងនេះ អាចមានធ្លាក់ឈាមតាមទ្វារមាស តែវានឹងបាត់ទៅវិញនៅប៉ុន្មានថ្ងៃខាងមុខ ប៉ុន្តែបើការធ្លាក់ឈាមនោះមានរយៈពេលយូរ និងបរិមាណច្រើន ត្រូវនាំអ្នកគាត់ត្រឡប់មកសេវាយើងវិញ ដើម្បីពិនិត្យ និងធ្វើការព្យាបាល ឬ ផ្តល់ប្រឹក្សាអំពីជំរើសថ្មីដល់គាត់។ សំណួរទី៣ តើផលរំខាននៃការប្រើ CoC និង POP អាចអោយក្តៅខ្លួន និងឈឺក្បាល ដែររឺទេ? កញ្ញាបានឆ្លើយថា ស្ត្រីមួយចំនួនបានរងផលរំខានដោយសារក្តៅខ្លួន និងឈឺ

ក្បាល តែអ្នកជំងឺអាចហូបទឹកអោយបានច្រើន ឬប្រើឱសថ Paracetamol ដើម្បីព្យាបាល ផលរំខាននេះ។

- ❖ **ការប្រើប្រាស់ឱសថពន្យាកំណើតដោយចាក់ បង្ហាញដោយកញ្ញា សែ សុខន**
- ❖ **ការបំពេញទំរង់ពន្យាកំណើត និងទំរង់ផ្សេងៗក្នុងការបង្ការជាវិជ្ជមានបង្ហាញដោយកញ្ញា សែ សុខន ដោយផ្តោតសំខាន់លើៈ**
  - ○ ទំរង់កំរងសំណួរ
  - ○ ទំរង់បញ្ជីចុះឈ្មោះអ្នកជំងឺប្រចាំថ្ងៃ និងទំរង់បញ្ជីចុះឈ្មោះស្ត្រីគោលដៅ ដែលឧបត្ថម្ភ
  - ○ ទំរង់ស្នើសុំថ្នាំពន្យាកំណើតៈ តើត្រូវស្នើសុំថ្នាំពន្យាកំណើតទាំងនោះ នៅឯណា? លោកវេជ្ជបណ្ឌិត សេង វុធី បានប្រាប់ថា ក្រុម OI/ART ត្រូវធ្វើសំណើរសុំថ្នាំទាំងនេះ ទៅមណ្ឌលសុខភាព រឺ មន្ទីរពេទ្យបង្អែកដែលនៅជិតបំផុត
  - ○ ទំរង់បាយការណ៍ប្រចាំថ្ងៃ និងប្រចាំខែៈ តើអ្នកណាជាអ្នកធ្វើរបាយការណ៍នេះ លោកវេជ្ជបណ្ឌិត សេង វុធី បានឆ្លើយថា អ្នកដែលត្រូវធ្វើរបាយការណ៍ គឺជាក្រុម OI/ART របស់មន្ទីរពេទ្យបង្អែកដែលបានផ្តល់សេវាទាំងនេះ ទៅអោយអតិថិជន។
- ❖ **កម្មវិធីបិទសិក្ខាសាលា**
  - ○ លោកវេជ្ជបណ្ឌិត **អោ វណ្ណថេន** ប្រធានមន្ទីរសុខាភិបាលខេត្តកំពង់ស្ពឺ បានមានចំណាប់អារម្មណ៍ក្នុងការបិទសិក្ខាសាលានេះថា ក្នុងនាមលោកជាថ្នាក់ដឹកនាំមន្ទីរសុខាភិបាល លោកមានសេចក្តីសោមនស្សរីករាយក្រៃលែង ដែលមជ្ឈមណ្ឌលជាតិទាំងពីរ បានរៀបចំដាក់អោយដំណើរការ នៅយុទ្ធសាស្ត្រនេះក្នុងខេត្តរបស់លោក ហើយជាចុងបញ្ចប់ លោកសូមលើកទឹកចិត្តមន្ត្រីសុខាភិបាលក្នុងស្រុកប្រតិបត្តិទាំងបីមេត្តាអនុវត្តនូវការងារនេះ ប្រកបដោយប្រសិទ្ធិភាព និងសូមថ្លែងអំណរគុណដល់មន្ត្រីសុខាភិបាលក្នុងខេត្តកំពង់ស្ពឺ និងមន្ត្រីដែលបានអញ្ជើញមកពីមជ្ឈមណ្ឌលជាតិទាំងពីរ ដែលបានខិតខំរៀន និងបង្រៀន ទោះបីជាការរៀបចំកម្មវិធីនេះ ស្ថិតចំថ្ងៃសំរាកក៏ដោយ និងជូនពរអោយគណៈអធិបតី លោក-លោកស្រីជួបតែសំណាងល្អ។
  - ○ ឯកឧត្តមវេជ្ជបណ្ឌិត មាន ឈីវុន ប្រធានមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ បានមានចំណាប់អារម្មណ៍ថាៈ តាំងនាមឯកឧត្តម តំណាងអោយមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ និងមជ្ឈមណ្ឌលជាតិគាំពារមាតា និងទាក សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះអស់លោក-លោកស្រី ដែលអញ្ជើញមកពីស្រុកប្រតិបត្តិទាំងបី, មន្ទីរសុខាភិបាលខេត្តកំពង់ស្ពឺ និងមជ្ឈមណ្ឌលជាតិទាំងពីរ ហើយឯកឧត្តមសង្ឃឹមយ៉ាងមុតមាំថា ពេលដែលបងប្អូនត្រឡប់ទៅវិញ បងប្អូននឹងរៀបចំដំណើរការនូវយុទ្ធសាស្ត្រនេះ ព្រោះថាវាជាគន្លឹះដ៏មានសារសំខាន់ក្នុងការបង្ការ ការពារ ដល់អ្នកដែលត្រូវការសេវានេះ ជាពិសេសអ្នកផ្ទុកមេរោគអេដស៍ និងអ្នកជំងឺអេដស៍ ម្យ៉ាងទៀតក្នុងគោលបំណង ដើម្បី

សំរេចអោយបាន តាមការប្តេជ្ញាចិត្តរបស់លោកជំទាវគតិព្រឹទ្ធបណ្ឌិត ប៊ុនរ៉ានី ហ៊ុន សែន។ ជាចុងក្រោយ ឯកឧត្តម សូមជូនពរអោយអស់លោក-លោកស្រី ត្រឡប់ទៅវិញប្រកបដោយសុវត្ថិភាព និងជួបប្រទះតែសេចក្តីសុខ និងសេចក្តីចំរើនគ្រប់ៗគ្នា

ភ្នំពេញ, ថ្ងៃទី ០៣ ខែ តុលា ឆ្នាំ ២០១១

អ្នកធ្វើរបាយការណ៍

កែវ វណ្ណៈ

បានឃើញ

ជ. ប្រធានមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺ

អេដស៍ សើស្បែក និងកាមរោគ

អនុប្រធាន

វេជ្ជ.លី-ពេញ ស៊ុន